អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣

នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ពីបទឧក្រិដ្ឋដូចខាងក្រោម៖ មនុស្សឃាត ដែលជាការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងទៀតដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តឥន្ទញាណ កំពង់សោម ក្រចេះ និងមន្ទីរសន្តិសុខ ស-២១ និងបានប្រព្រឹត្តលើជនជាតិវៀតណាម ជនជាតិថៃ និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះ ដែលកម្ពុជាប្រជាធិបតេយ្យបានអះអាងថាស្ថិតនៅក្រោមអធិបតេយ្យភាពរបស់ខ្លួន និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩(តាមរយៈការប្រព្រឹត្តិបទឧក្រិដ្ឋដែលក្នុងនោះមាន ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការធ្វើមនុស្សឃាតដោយចេតនា ការនិរទេស ឬការផ្លាស់ទីដោយខុសច្បាប់ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្ម)ដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនៅកំពង់សោម ក្រចេះ និងមន្ទីរសន្តិសុខ ស-២១ និងបានប្រព្រឹត្តលើជនជាតិវៀតណាម ជនជាតិថៃ និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះ ដែលកម្ពុជាប្រជាធិបតេយ្យបានអះអាងថាស្ថិតនៅក្រោមអធិបតេយ្យភាពរបស់ខ្លួន។

ដោយសារការដាក់ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ពីបទចោទប្រកាន់ទាំងនេះ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អនុញ្ញាតឲ្យ មាស មុត តាមរយៈមេធាវីរបស់គាត់ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ ដូច្នេះនឹងជួយបង្កើនល្បឿនដំណើរការស៊ើបសួរ។ ការធ្វើដូច្នេះនឹងអនុញ្ញាតឲ្យកិច្ចស៊ើបសួរ ដំណើរការបានទៅដោយគោរពសិទ្ធិរបស់ភាគីទាំងអស់បានពេញលេញ និងអាចបញ្ចប់កិច្ចស៊ើបសួរក្នុងថិរវេលាសមស្រប ហើយនឹងចេញដីកាដំណោះស្រាយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក ឡាស អូលសិន
មន្ត្រីច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh